# នាងវិសាខា មហាឧបាសិកា

## មុនពុទ្ធកាល

ក្នុងកាលព្រះពុទ្ធព្រះនាម បទុមុត្តរៈ នាងកើតនៅនគរ ហំសវតី ។ ដល់ខាងក្រោយមកបានស្ដាប់នូវធម្មទេសនានៃព្រះពុទ្ធ ហើយបានឃើញឧបាសិកាម្នាក់ដែលព្រះបរមសាស្ដាបានតែងតាំងក្នុងទីដ៏ប្រសើរថាជាអ្នកបានឱ្យនូវទាន ។ ចាប់ពីពេលនោះមក នាងបានធ្វើបុណ្យកុសលយ៉ាងច្រើនក្រៃលែង ដើម្បីប្រាថ្នាឱ្យបាននូវឋានន្តរៈនោះ ។

## សម័យពុទ្ធកាល

អន្ទោលទៅមកអស់ជាច្រើនកប្ប លុះដល់មកសម័យពុទ្ធកាលព្រះសមណគោតម នាងបានមកកើតក្នុងផ្ទៃនៃនាងសុមនទេវី ជាមហេសីនៃធនញ្ជយសេដ្ឋីដែលជាបុត្រមេណ្ឌកសេដ្ឋីក្នុងភទ្ទិយនគរ ក្នុងដែនអង្គៈនាក្រុងរាជគ្រឹះមគធរដ្ឋ មានឈ្មោះថា វិសាខា ។

## សម្រេចសោតាបត្តិផល

ក្នុងសម័យពុទ្ធកាល ព្រះរាជាណាចក្រពិម្ពិសារមហារាជមានសេដ្ឋីមហាសាលគឺអ្នកមានទ្រព្យច្រើនរាប់មិនអស់ចំនួន៥នាក់ដែលក្នុងនោះមានមេណ្ឌកសេដ្ឋីផងដែលត្រូវជាជីតាបង្កើតនៃនាងវិសាខា ។ បណ្ដាសេដ្ឋីមហាសាលទាំង៥នាក់នោះ មានតែមេណ្ឌកសេដ្ឋីទេដែលមានការរាប់អានជិតស្និទ្ធនិងស្រឡាញ់ចូលចិត្តព្រះសាស្ដាណាស់ ។ ថ្ងៃមួយព្រះសាស្ដាទ្រង់យាងមកភទ្ទិយនគរដែលជានគររបស់ខ្លួន មេណ្ឌកសេដ្ឋីហៅនាងវិសាខាជាចៅស្រីព្រមទាំងបរិវាររបស់នាងចំនួន៥០០នាក់ ដើម្បីទៅទទួលព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់សំដែងធម្មទេសនា លុះស្ដាប់ចប់ មេណ្ឌកសេដ្ឋីនិងចៅស្រីវិសាខាព្រមទាំងបរិវារទាំង៥០០របស់នាងបានសម្រេចសោតាបត្តិផលទាំងអស់គ្នា ។

## ការផ្លាស់ប្ដូរទីលំនៅ

ព្រះរាជាក្រុងសាវត្ថីព្រះនាមបសេនទិបានផ្ញើព្រះរាជសារនឹងរាជបុរសទៅកាន់សំណាក់ព្រះរាជាក្រុងរាជគ្រឹះទ្រង់ព្រះនាមពិម្ពិសារថា អាណាចក្ររបស់ខ្ញុំព្រះអង្គមិនមានត្រកូលអមិតភោគាគឺអ្នកមានទ្រព្យច្រើនរាប់មិនអស់ដូចអាណាចក្ររបស់ព្រះអង្គទេ ដូច្នេះសូមព្រះអង្គទ្រង់មេត្តាបញ្ជូនត្រកូលអមិតភោគាដល់យើង

ខ្ញុំ ។ ព្រះរាជាពិម្ពិសារទ្រង់ប្រឹក្សាជាមួយនឹងអាមាត្យទាំងឡាយហើយសម្រេចព្រះទ័យបញ្ជូនសេដ្ឋីបុត្រម្នាក់ដែលត្រូវជាបុត្រមេណ្ឌកសេដ្ឋីឈ្មោះធនញ្ជយសេដ្ឋីតាមសេចក្តីស្នើសុំរបស់ព្រះចៅក្រុងសាវត្ថី ។ ពេលនោះព្រះរាជាបសេនទិកោសលទ្រង់បានកំណត់នូវទីកន្លែងមួយដែលមានចម្ងាយ៧យោជន៏ពីទីក្រុងសាវត្ថីឈ្មោះសាកេតនគរសម្រាប់ជាកម្មសិទ្ធិផ្ទាល់ដល់ក្រុមគ្រួសារធនញ្ជយសេដ្ឋីជាបិតានាងវិសាខា ។

## នាងវិសាខារៀបមង្គលការ

នៅក្រុងសាវត្ថីមានបុត្ររបស់មិគារសេដ្ឋីម្នាក់ឈ្មោះបុណ្ណវឌ្ឍនកុមារ ។ កាលមានវ័យចម្រើនគ្រប់គ្រាន់ហើយ បិតាក៏នឹកចង់រៀបចំគ្រួសារឱ្យកូនហើយបញ្ជូននូវបុរសទាំងឡាយឱ្យស្វែងរកស្ត្រីបញ្ចពិធកល្យាណីដែលមានត្រកូលស្មើនឹងខ្លួន ។ បុរសទាំងឡាយបានដើររកសព្វច្រកល្ហកក្នុងក្រុងសាវត្ថីមិនឃើញមានស្ត្រីណាជាទីគាប់ចិត្តរបស់ខ្លួន ក៏បន្តដំណើរចូលទៅក្រុងសាកេត ។ ក្នុងថ្ងៃនោះឯង នាងវិសាខាព្រមទាំងបរិវារ៥០០នាក់ដែលមានវ័យស្មើនឹងខ្លួនបានធ្វើដំណើរទៅកាន់ស្រះធំមួយ ។ ពេលនោះភ្លៀងធ្លាក់ចុះយ៉ាងខ្លាំងបរិវារទាំង៥០០នាក់រត់ប្រញាប់ប្រញាល់ចូលទៅកាន់សាលាសំណាក់ដើម្បីកុំឱ្យទទឹក ចំណែកនាងវិសាខាបានដើរសន្សឹមៗចូលទៅជ្រកក្រោយគេ ។ បុរសទាំងឡាយឃើញហើយ ក៏ត្រូវចិត្តពេញចិត្តទាំងស្រុងហើយគិតថា នេះជាស្ត្រីបញ្ចពិធកល្យាណីដែលកម្រមានក្នុងជម្ពូទ្វីបទើបទៅបំពាក់នូវកម្រងផ្កាដល់នាង ។ បុរសទាំងឡាយត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញដើម្បីប្រាប់ដំណឹងពីបានជួបស្ត្រីបញ្ចពិធកល្យាណីវិសាខាជាធីតានៃធនញ្ជយសេដ្ឋីក្នុងក្រុងសាកេត ។ មិគារសេដ្ឋីក្រុងសាវត្ថីមានចិត្តត្រេកអរណាស់ដោយដឹងថា នាងវិសាខាជាធីតានៃមហាត្រកូល ។ មិគារសេដ្ឋីនិងធនញ្ជយសេដ្ឋីក៏ចាប់ផ្តើមរៀបមង្គលការដល់កូនប្រុសកូនស្រីយ៉ាងមហោឡារឹកអស់ចំនួន៤ខែ ទាល់តែជាងធ្វើហើយនូវអាវពិសេសប្រដាប់សុទ្ធតែមាសនិងពេជ្រអស់តម្លៃ២៧កោដិកហបណៈដែលបិតាបានបញ្ជាឱ្យជាងមាសចំនួន៥០០នាក់ធ្វើជូនជាចំណងដៃដល់នាងសម្រាប់ពាក់ក្នុងពិធីមង្គលការ ។

## នាងវិសាខាទៅនៅឯផ្ទះប្តី

មុននឹងបញ្ជូននាងវិសាខាឱ្យទៅកាន់ផ្ទះត្រកូលខាងប្តី ធនញ្ជយសេដ្ឋីជាបិតាបាននិយាយប្រដែប្រដៅព្រមទាំងអប់រំនាងឱ្យគោរពតាមច្បាប់ស្រីចំនួន១០ចំណុច ។ បិតាបានរើសព្រាហ្មណ៍ចំនួន៨នាក់ឱ្យទៅធានារក្សានាងគឺប្រសិនបើមានទោសកំហុសកើតឡើងដល់នាងក្នុងទីដែលរស់នៅនោះគប្បីជម្រះឱ្យស្អាត ហើយនិងចែកទ្រព្យសម្បត្តិយ៉ាងច្រើនមហិមា ។ ពេលធ្វើដំណើរពីក្រុងសាកេតមកកាន់ក្រុងសាវត្ថីដែលមាន

ចម្ងាយ៧យោជន៍ ប្រជាជនណែនណាន់តាន់តាប់ឈរចាំទទួលជាកិត្តិយសដល់នាងវិសាខា ។ នាងបាន បង្ហាញខ្លួនដល់អ្នកនគរឱ្យគេមើលគ្រប់គ្នាដោយនាងឈរលើរថសេះដែលបរសន្សឹមៗចូលទៅកាន់ក្រុង សាវត្ថី ។ អ្នកនគរបានបញ្ជូនបណ្ណាការគ្រប់យ៉ាងដល់នាងដើម្បីជាមហាសក្ការៈនិងទុកនាងជាមហា សម្បត្តិកិត្តិយសដល់នគររបស់ខ្លួន ។ គ្រឿងបណ្ណាការទាំងអស់នោះ នាងវិសាខាបានចែកទានដល់ត្រកូល ក្រីក្រអស់គ្មានសល់ ។

## នាងវិសាខាមានវិបត្តិជាមួយឪពុកក្មេក

រស់នៅជាមួយឪពុកក្មេកបានចំនួន៦ថ្ងៃ នាងវិសាខាពុំដែលឃើញគាត់អញ្ជើញទៅកាន់សំណាក់ព្រះសាស្តា ម្តងណាសោះឡើយ ទោះបីផ្ទះនៅជិតវត្តជេតពនក៏ដោយ ។ លុះដល់ថ្ងៃទី៧ គេឃើញមានរៀបចំធ្វើ សក្ការៈពេញក្នុងទីលំនៅសេដ្ឋីជាបិតាក្មេកដោយមានសមណៈអាក្រាតអង្គុយពេញត្រៀបត្រា ។ មិគារសេដ្ឋី បានឱ្យនាងវិសាខាមកថ្វាយបង្គំសមណៈអាក្រាតដោយទុកថាជាព្រះអរហន្ត ។ នាងមិនព្រមធ្វើតាមហើយ ដើរត្រឡប់ចូលទៅកាន់កន្លែងនាងវិញ ។ សមណៈអាក្រាតឃើញដូច្នោះក៏ត្អះតិះដៀលមិគារសេដ្ឋីថា ម៉េច ក៏យកស្ត្រីមហាកាឡកិណ្ណីជាសាវិកាសមណគោតមមកទុកនៅផ្ទះ ចូរបណ្តេញចេញទៅវិញឆាប់ៗ ។ មិគារសេដ្ឋីឆ្លើយថា មិនអាចធ្វើតាមបានភ្លាមៗទេព្រោះនាងជាមហាត្រកូលហើយមានព្រាហ្មណ៍តាមមកថែ រក្សាការពារផង ។

ថ្ងៃមួយមានព្រះថេរៈមួយអង្គនិមន្តត្រាច់ទៅបិណ្ឌបាតដល់ទ្វារផ្ទះសេដ្ឋីនៅពេលដែលសេដ្ឋីកំពុងតែបរិភោគ បាយ ។ សេដ្ឋីឃើញព្រះថេរៈ តែធ្វើហាក់ជាមិនឃើញហើយឱនមុខចុះបន្តការបរិភោគបាយជាធម្មតា ។ នាងវិសាខាឃើញដូច្នោះក៏ពោលទៅកាន់ព្រះថេរៈថា ឪពុកក្មេករបស់ខ្ញុំករុណាទំពាស៊ីនូវអាហារចាស់ទេ លោកម្ចាស់ ។ លោកសេដ្ឋីយល់ថា នាងវិសាខាមើលងាយខ្លួន ខឹងណាស់ក៏បណ្តេញនាងឱ្យចុះចេញពី ផ្ទះ ។ នាងពោលទៅកាន់លោកសេដ្ឋីថា បពិត្រលោកឪពុក ខ្ញុំមិនចុះចេញដោយហេតុប៉ុណ្ណេះឡើយ ហើយនាងហៅព្រាហ្មណ៍ទាំង៨នាក់ដែលតាមមកមើលការខុសត្រូវចំពោះរូបនាងឱ្យមកជួបជុំនៅមុខលោក សេដ្ឋីដើម្បីពន្យល់ឱ្យយល់ច្បាស់ថា នាងវិសាខាមិនមានកំហុសអ្វីទេ ។ មិគារសេដ្ឋីដឹងនូវកំហុសខុសឆ្គង របស់ខ្លួន ក៏និយាយសូមអង្វរករព្រាហ្មណ៍ទាំង៨នាក់និងនាងវិសាខាឱ្យអត់ឱនទោសដល់ខ្លួន ។ ព្រាហ្មណ៍ ឆ្លើយថា យើងខ្ញុំទាំងអស់គ្នាអត់ទោសឱ្យលោកបាន តែចំពោះនាងវិសាខាដែលធ្លាប់តែមានសទ្ធាមុតមាំ ក្នុងព្រះពុទ្ធសាសនានឹងឱ្យនាងវៀរចាកព្រះសង្ឃមិនបានជាដាច់ខាត ប្រសិនជាលោកសេដ្ឋីអនុញ្ញាតឱ្យនាង បានទំនុកបំរុងព្រះសង្ឃដោយពេញចិត្ត យើងខ្ញុំទាំងអស់គ្នានឹងសុខចិត្តនៅជាមួយលោកតទៅទៀតបាន ។ មិគារសេដ្ឋីបានយល់ព្រមតាមទាំងស្រុងហើយពោលទៅកាន់នាងវិសាខាថា ចូរនាងធ្វើការទំនុកបំរុងដល់

សមណៈរបស់នាងតាមសេចក្ដីគាប់ចិត្តចុះ ។

## នាងវិសាខាមានឈ្មោះថា មិគារមាតា

មួយថ្ងៃក្រោយមក នាងវិសាខាបាននិមន្តព្រះភិក្ខុសង្ឃមានព្រះសាស្ដាជាប្រធានមកគង់ត្រៀបត្រាក្នុងទីលំនៅរបស់នាងដើម្បីទទួលភត្ត ។ នាងបានអញ្ជើញឪពុកក្មេកឱ្យមកអង្គាសចង្ហាន់ដល់ព្រះសាស្ដា ។ លុះចប់ភត្តកិច្ច នាងបានប្រាប់ឪពុកក្មេកឱ្យស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ។ ដោយទើសទាល់ខ្លាំងពេកនឹងនាងវិសាខា មិគារសេដ្ឋីក៏សុខចិត្តអង្គុយស្ដាប់ខាងក្រៅវាំងនន ។ ព្រះសាស្ដាគិតថា អ្នកអង្គុយខាងក្រៅវាំងននក្ដី ខាងក្រៅជញ្ជាំងក្ដី ខាងក្រៅចក្រវាឡដទៃក្ដី តថាគតឈ្មោះថាព្រះសម្មាសម្ពុទ្ធជាអ្នកធ្វើឱ្យអ្នកស្ដាប់ឮនូវសម្លេងធម្មទេសនារបស់តថាគតបាន ។ លុះចប់ធម្មទេសនាហើយ មិគារសេដ្ឋីបានតម្កល់ក្នុងសោតាបត្តិផលហើយបើកវាំងននលូនចេញមកថ្វាយបង្គំព្រះបាទាព្រះបរមសាស្ដា រួចចូលទៅអង្គុយជិតព្រះសាស្ដាហើយពោលទៅកាន់នាងវិសាខាថា ម្នាលនាងវិសាខាដ៏ចម្រើន ! ចាប់តាំងពីថ្ងៃនេះទៅ នាងទុកដូចជាមាតារបស់ខ្ញុំគឺតម្កល់នាងវិសាខាក្នុងឋានៈជាមាតារបស់ខ្លួន ។ ចាប់តាំងពីពេលនោះមក នាងវិសាខាមាននាមថា មិគារមាតាដែលមានន័យថា ម្ដាយរបស់មិគារសេដ្ឋី ៕